

ព្រះរាជាណាចក្រកម្ពុជា

Kingdom of Cambodia

# លំនាំបទដ្ឋាន

## ការគ្រប់គ្រងការពារបេតិកភណ្ឌវប្បធម៌អរូបី នៅតំបន់បេតិកភណ្ឌពិភពលោកអង្គរ និងតំបន់ផ្សេងៗទៀត ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់អាជ្ញាធរអប្សរា

# GUIDELINES

## Safeguarding Intangible Cultural Heritage within the Angkor World Heritage Site and other Sites under the Jurisdiction of APSARA Authority

## អ្នកចាត់ចែងបោះពុម្ព :

យួន យុនណាយ

## ក្រុមបច្ចេកទេសតាក់តែងលំនាំបទដ្ឋាន :

| | |
|---|---|
| ចៅ ស៊ុន គិរិយា | ទីប្រឹក្សា |
| យួន យុនណាយ | ទីប្រឹក្សា |
| ហង់ ពៅ | ទីប្រឹក្សា |
| អាំង ផូលាន | ប្រធានក្រុម |
| អ៊ឹម សុខរិទ្ធី | អនុប្រធានក្រុម |
| អ៊ា ដារិទ្ធ | សមាជិក |
| ខៀវ ច័ន្ទ | សមាជិក |
| ស្រ៊ុន តិច | សមាជិក |
| ហេង ថាន | សមាជិក |
| ហេង សុខា | សមាជិក |
| ឯម គឹមស្រ៊ាង | សមាជិក |
| គឹម សំណាង | សមាជិក |

## អ្នកពិគ្រោះយោបល់ :

**Georgina LLOYD**

## អ្នករចនាទំព័រ :

កញ្ញា ហ៊ីរ រិទ្ធារ័ត្ន — អ្នកជំនាញព័ត៌មានវិទ្យា

## មាតិកា :


កំណត់របស់អ្នកចាត់ចែងបោះពុម្ព ........ ៤

គោលបំណងនៃលំនាំបទដ្ឋាន ........ ៦

ឯកសារយោង ........ ៦

បទដ្ឋាន ........ ៦

១. ការស្រាវជ្រាវ និង ចុះបញ្ជី ........ ៩

២. សិទ្ធក្នុងវិស័យវប្បធម៌ ........ ១០

៣. សហគមន៍ និង មធ្យោបាយរស់នៅ ........ ១១

៤. ការអប់រំ ........ ១២

៥. ការចូលរួម ........ ១៣

៦. ការបង្កើនចំណាប់អារម្មណ៍ពីទេសចរណ៍ ........ ១៣

៧. ការទទួលស្គាល់ ........ ១៤

៨. ការពិនិត្យឡើងវិញ ........ ១៥



គាំទ្រដោយកម្មវិធីជំនួយប្រទេសញូវហ្សឺឡែន

NEW ZEALAND

# លំនាំបទដ្ឋាន

## ស្តីអំពី

## ការគ្រប់គ្រងការពារបេតិកភណ្ឌវប្បធម៌អរូបី នៅតំបន់បេតិកភណ្ឌពិភពលោកអង្គរ និងតំបន់ផ្សេងៗទៀត ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់អាជ្ញាធរអប្សរា

ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៣

United Nations Educational, Scientific and Cultural Organization

Intangible Cultural Heritage

អាជ្ញាធរអប្សរា

APSARA

# កំណត់របស់អ្នកចាត់ចែងបោះពុម្ព

អាជ្ញាធរអប្សរា មានភារកិច្ចថែរក្សាការពារឧទ្យានអង្គរទាំងមូល ស្របទៅតាមអនុសញ្ញានៃអង្គការ **UNESCO** ហើយលើកតម្កើងវប្បធម៌ខ្មែរទាំងរូបី ទាំងអរូបី ដោយយល់យ៉ាងច្បាស់ថា ទំនាក់ទំនងរវាងរមណីយដ្ឋាន និងប្រជាពលរដ្ឋ ពុំអាចផ្តាច់ចេញពីគ្នាបានឡើយ ដូចជាគេពុំអាចផ្តាច់ព្រលឹងពីខ្លួនមនុស្សបានដូច្នោះដែរ លើកលែងតែដល់ពេលដែលបុគ្គលនោះស្លាប់ ។

បេតិកភណ្ឌអរូបី ចេះតែបាត់បង់សាបរលាបបន្តិចម្តងៗជាលំដាប់ ។ បើគ្មានការប្រឹងប្រែងថែរក្សានូវអ្វីដែលសេសសល់ទេ អាចប្រឈមនឹងការបាត់បង់ទាំងស្រុង ហើយអត្តសញ្ញាណនៃជាតិខ្មែរយើង នឹងរលត់នាពេលនោះដែរ ។ អាជ្ញាធរអប្សរាបានខំប្រឹងប្រែងធ្វើការស្រាវជ្រាវកត់ត្រាទុកជាបណ្តើរៗតាំងពីឆ្នាំ២000 ដោយបានបង្កើតក្រុម "**សិក្សាសង្គម**" ។ បន្ទាប់មកទៀតក៏បានបញ្ចូលសកម្មភាពនេះទៅក្នុងគម្រោង "**រស់នៅជាមួយបេតិកភណ្ឌ**" **(Living with Heritage)** ដោយសហការជាមួយសកលវិទ្យាល័យស៊ីដនី ប្រទេសអូស្ត្រាលី ។ ចាប់ពីឆ្នាំ២00៩មក អាជ្ញាធរអប្សរាក៏បានបញ្ចូលផ្នែកបេតិកភណ្ឌអរូបីជាផ្នែកមួយនៃ "**គម្រោងគ្រប់គ្រងធនធានធម្មជាតិ និង អភិវឌ្ឍន៍ជីវភាពរស់នៅក្នុងតំបន់អង្គរ ដោយមានការចូលរួមពីប្រជាជន**" **(Angkor Participatory Natural Resource Management & Livelihoods - APNRM&L)** ដោយសហការជាមួយប្រទេសញូវហ្ស៊ីឡែន ។

ទន្ទឹមគ្នានេះដែរ អាជ្ញាធរអប្សរាក៏បានបង្កើតគម្រោង "**ការស្រាវជ្រាវបេតិកភណ្ឌអរូបី នៅក្នុងឧទ្យានអង្គរ**" នៅថ្ងៃ ទី២៩ ខែមេសា ឆ្នាំ២០១០ ។ ក្រុមការងារនៃគម្រោងបានរៀបចំតាក់តែងពង្រាង "**លំនាំបទដ្ឋានស្តីអំពី ការគ្រប់គ្រងការពារបេតិកភណ្ឌវប្បធម៌អរូបី នៅតំបន់បេតិកភណ្ឌពិភពលោកអង្គរ និងតំបន់ផ្សេងៗទៀត ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់អាជ្ញាធរអប្សរា**" ។ នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១០ ថ្នាក់ដឹកនាំអាជ្ញាធរអប្សរាទាំងមូលបានប្រជុំគ្នា ពិនិត្យលើពង្រាងបទដ្ឋាននេះ ហើយបានជួយកែលំអរួចជាស្រេច ។

អាជ្ញាធរអប្សរារៀបចំសិក្ខាសាលាស្តីអំពី "**ការការពារ និង អភិវឌ្ឍន៍បេតិកភណ្ឌអរូបី នៅក្នុងឧទ្យានអង្គរ**" នាថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៣ នេះឡើង គឺដើម្បីពិគ្រោះគ្នាជាលក្ខណៈទូលំទូលាយ លើពង្រាងលំនាំបទដ្ឋាននៃការការពារ និង អភិវឌ្ឍន៍បេតិកភណ្ឌអរូបី

នៅក្នុងឧទ្យានអង្គរ ដោយបាននិមន្តព្រះសង្ឃ អញ្ជើញអាជ្ញាធរមូលដ្ឋាន ព្រមទាំងចាស់ទុំព្រឹទ្ធាចារ្យក្នុងភូមិ-ឃុំ មកចូលរួម។ សិក្ខាសាលាបានពិនិត្យ ហើយប្តូរយោបល់គ្នាយ៉ាងផុសផុល លើលំនាំបទដ្ឋាន **"លំនាំបទដ្ឋានស្តីអំពីការគ្រប់គ្រងការពារ និងអភិវឌ្ឍន៍បេតិកភណ្ឌអរូបី នៅតំបន់បេតិកភណ្ឌពិភពលោកអង្គរ និងតំបន់ផ្សេងៗទៀត ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់អាជ្ញាធរអប្សរា"** ហើយបានសម្រេចយកជាយន្តការមួយយ៉ាងជាក់លាក់រឹងមាំ ក្នុងការអភិរក្ស និង អភិវឌ្ឍន៍បេតិកភណ្ឌអរូបីក្នុងឧទ្យានអង្គរ ឱ្យបានប្រកបដោយចីរភាពតរៀងទៅ។

ក៏ប៉ុន្តែ ការដែរមានយន្តការនេះមិនទាន់គ្រប់គ្រាន់ទេ គឺចាំបាច់ត្រូវតែមានការចូលរួមអនុវត្តយ៉ាងសកម្មឱ្យបានខ្ជាប់ខ្ជួន។ អារ្យធម៌វប្បធម៌ជាតិ ជាកតាព្វកិច្ចរបស់រាជរដ្ឋាភិបាលគ្រប់ជាន់ថ្នាក់ និងប្រជាពលរដ្ឋគ្រប់រូប មានទាំងព្រះសង្ឃ ទាំងគ្រហស្ថ ទាំងចាស់ ទាំងក្មេង ទាំងអស់គ្នា។

កូនសៀវភៅនេះ មានគោលបំណងផ្សព្វផ្សាយលំនាំបទដ្ឋានជាសាធារណៈទូទៅ ដើម្បីឱ្យបានយល់ដឹងពីការងារសំខាន់ក្នុងការគ្រប់គ្រងការពារបេតិកភណ្ឌអរូបី។

សៀមរាប, ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៣



**ឃួន ឃុននាយ**
អគ្គនាយករងអាជ្ញាធរអប្សរា
ទទួលបន្ទុកនាយកដ្ឋានរៀបចំដែនដី និងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរ
ប្រធានគណៈកម្មការបច្ចេកទេសអនុវត្តគម្រោងសហការរវាងអាជ្ញាធរអប្សរា-ញូវហ្ស៊ីឡែន

# គោលបំណងនៃលិខិតបទដ្ឋាន

**គោលបំណងនៃបទដ្ឋាននេះមានដូចតទៅ ៖**

ក. ការពារបេតិកភណ្ឌវប្បធម៌អរូបី ដែលមិនអាចផ្តាច់ចេញបានពីបេតិកភណ្ឌរូបី នៅតំបន់អង្គរ និងនៅតំបន់ផ្សេងៗទៀត ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់អាជ្ញាធរអប្សរា។

ខ. ទទួលស្គាល់សិទ្ធិ និង សេរីភាព របស់អ្នកស្រុកចំពោះបេតិកភណ្ឌអរូបី និងករណីយកិច្ចអ្នកស្រុក ក្នុងការ គោរព រក្សា និងទទួលផលវិជ្ជមានពីមរតកនោះ។

គ. បង្កើនចំណាប់អារម្មណ៍ លើការការពារបេតិកភណ្ឌរូបីនិងអរូបី ស្របទៅតាមសន្ធិសញ្ញានានា របស់អង្គការ UNESCO ជាពិសេសបង្កើនចំណាប់អារម្មណ៍ក្នុងរង្វង់អាជ្ញាធរអប្សរានិងសាធារណជនទូទៅ អំពីសារៈសំខាន់នៃបេតិកភណ្ឌវប្បធម៌អរូបី ព្រមទាំងកាតព្វកិច្ចរបស់ប្រទេសកម្ពុជា ក្នុងការថែរក្សាមរតកនេះ។

ឃ. ជំរុញឱ្យមានការគោរព និងលើកតម្លៃបេតិកភណ្ឌវប្បធម៌អរូបី ដែលជាផ្នែកមួយនៃមរតកដ៏ធំធេង នៃប្រទេសកម្ពុជា និងជាប្រភពមួយនៃអត្តសញ្ញាណជាតិ។

# យោង ៖

- ដោយទទួលស្គាល់ថា ប្រទេសកម្ពុជាជាប្រទេសហត្ថលេខីលើសន្ធិសញ្ញា ស្តីពីការការពារបេតិកភណ្ឌវប្បធម៌ និងបេតិកភណ្ឌធម្មជាតិពិភពលោក (១៩៧២) និងអនុសញ្ញាស្តីពីការការពារបេតិកភណ្ឌ វប្បធម៌អរូបី (២០០៣)
- ដោយឃើញថាអនុសញ្ញាទាំងពីរនេះ ការពារផ្នែកសំខាន់ៗនៃបេតិកភណ្ឌដែលមាននៅតំបន់អង្គរ ហើយដែលត្រូវតែអនុវត្ត ដើម្បីថែរក្សាឱ្យគង់វង្សនូវបេតិកភណ្ឌវប្បធម៌នៃប្រទេសកម្ពុជាទៅអនាគត

- ដោយទទួលស្គាល់អនុសញ្ញាអង្គការ UNESCO ស្តីពីការការពារនិងលើកស្ទួយភាពផ្សេងៗគ្នា នៃវិញ្ញត្តិវប្បធម៌ (២០០៥)
- ដោយយោងតាមព្រះរាជក្រមលេខ នស/រកម/០១០៦/០០៣ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការអនុម័តយល់ព្រមលើអនុសញ្ញាស្តីពីការការពារបេតិកភណ្ឌវប្បធម៌អរូបី
- ដោយយោងតាមព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៩ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលជាភាគីហត្ថលេខីនៃអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីការការពារនិងលើកស្ទួយភាពផ្សេងៗគ្នានៃវិញ្ញត្តិវប្បធម៌
- ដោយយោងតាមព្រះរាជក្រឹត្យលេខ០០១/នស. ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៤ ស្តីពីការកំណត់ និងការចាត់ចែងគ្រប់គ្រងតំបន់សៀមរាប-អង្គរ
- ដោយយោងតាមព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់សៀមរាប-អង្គរ ហៅថា **"អាជ្ញាធរអប្សរា"** និងការកែប្រែ ព្រមទាំងនីតិក្រមពាក់ព័ន្ធដែលមានតមកទៀត
- ដោយយោងតាមសេចក្តីសម្រេចលេខ៧០សសរ. ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពីការកំណត់បទដ្ឋាននៃការប្រើប្រាស់ដីធ្លីនៅតំបន់១ និងតំបន់២ ក្នុងរមណីយដ្ឋានសៀមរាប-អង្គរ
- ដោយយោងតាមព្រះរាជក្រឹត្យលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីច្បាប់ការពារបេតិកភណ្ឌវប្បធម៌
- ដោយយោងតាមព្រះរាជក្រឹត្យលេខ នស/រកត/០២១០/១៦៣ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១០ ស្តីពីប្រព័ន្ធមរតកមនុស្សរស់នៃព្រះរាជាណាចក្រកម្ពុជា

- ដោយទទួលស្គាល់ថា អនុក្រឹត្យលេខ៥០/អ.ន.ក./ប.ក. ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០០៨ បានចែងថា អាជ្ញាធរអប្សរាមានភារកិច្ចការពារលំនៅដ្ឋានប្រពៃណី សំណង់សាសនា ស្របទៅតាមអនុសញ្ញានានានៃអង្គការ UNESCO, ផ្សព្វផ្សាយចំណេះដឹងនិងលទ្ធផលស្រាវជ្រាវអំពីវប្បធម៌ខ្មែរ, បង្កើនការយល់ដឹងអំពីតម្លៃបេតិកភណ្ឌ, បង្កើនការគោរពចំពោះបេតិកភណ្ឌ និងលើកតម្កើងវប្បធម៌ខ្មែរ ទាំងរូបី ទាំងអរូបី
- ដោយទទួលស្គាល់សេចក្តីសម្រេចរបស់អង្គការ UNESCO ចុះបញ្ជីរបាំក្បាច់បុរាណខ្មែរ (៧ វិច្ឆិកា ២០០៣) និងល្ខោនស្បែកធំខ្មែរ (២៥ វិច្ឆិកា ២០០៥) ជាសម្បត្តិវប្បធម៌អរូបីនៃមនុស្សជាតិ
- ដោយជ្រួតជ្រាបថា បេតិកភណ្ឌអរូបីដែលគង់វង្សតទៅទៀតនោះ មានសារៈសំខាន់បំផុតក្នុងការរក្សាតម្លៃព្រលឹងអង្គរ
- ដោយទទួលស្គាល់ថា ទំនាក់ទំនងរវាងរមណីយដ្ឋានបេតិកភណ្ឌអង្គរ និងប្រជាជនក្នុងតំបន់នោះ ពុំអាចផ្តាច់ចេញពីគ្នាបាន
- ដោយយល់ឃើញថា ជាការធម្មតាទេដែលអ្នកស្រុកតែងប្រើប្រាស់រមណីយដ្ឋានក្នុងសាសនា និងកិច្ចបូជាផ្សេងៗ។

# បទដ្ឋានសម្រាប់ការពារបេតិកភណ្ឌវប្បធម៌អរូបី ត្រូវបានអនុវត្តដូចតទៅ ៖

## ១. ការស្រាវជ្រាវ និងចុះបញ្ជី

**១.១** ការស្រាវជ្រាវជាការងារមូលដ្ឋាន ដើម្បីយល់តម្លៃបេតិកភណ្ឌអរូបី។ កម្មវិធីស្រាវជ្រាវមួយនឹងត្រូវបង្កើតឡើង ដើម្បីស្វែងយល់អំពីបេតិកភណ្ឌវប្បធម៌អរូបីគ្រប់បែបយ៉ាង ដែលមានក្នុងតំបន់គ្រប់គ្រងដោយអាជ្ញាធរអប្សរា។ ក្រុមស្រាវជ្រាវមួយនឹងត្រូវបង្កើតឡើង ដោយមាននាទីពិសេសនឹងប្រមូលទិន្នន័យនានា ពាក់ព័ន្ធនឹងបេតិកភណ្ឌវប្បធម៌អរូបី ដែលមានក្នុងតំបន់គ្រប់គ្រងដោយអាជ្ញាធរអប្សរា។

**១.២** **បេតិកភណ្ឌវប្បធម៌អរូបីនៅអង្គរ មានជាអាទិ៍ ៖**

ដោយយោងតាមព្រះរាជក្រឹត្យលេខ ន.ស./រ.ក.ត/០២១០/១៦៣ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១០ ស្ដីពីប្រព័ន្ធមរតកមនុស្សរស់នៃព្រះរាជាណាចក្រកម្ពុជា,

ក. ចំណេះដឹងដែលនិទានតគ្នាដូចជារឿងនានាមាន ទេវកថា, រឿងព្រេង (រាប់បញ្ចូលទាំងប្រវត្តិសហគមន៍ និងឈ្មោះភូមិស្រុក) សុភាសិត, ពាក្យទំនៀម, ចម្រៀង ។ល។

ខ. សិល្បៈនានាដូចជា គំនូរលើជញ្ជាំង, អាយ៉ង, ល្ខោនគ្រប់បែបយ៉ាង, របាំ, ភ្លេង ។ល។

គ. បុណ្យទាននិងកិច្ចពិធីគ្រប់ប្រភេទ ជាលក្ខណៈជីវចល, ពុទ្ធសាសនា, ព្រហ្មញ្ញសាសនា (ហើយដែលច្រើនតែលាយឡំចូលគ្នាផង) ដូចជាពិធីឆ្លងវ័យ, ពិធីទាក់ទងនឹងកសិកម្ម, ទាក់ទងនឹងការសាងសង់ ។ល។

ឃ. ចំណេះដឹងជាប្រពៃណី និងទេពកោសល្យអំពីស្ថាបត្យកម្ម, សិប្បកម្ម, វិជ្ជាធ្វើម្ហូប, ព្យាបាលរោគ, ទស្សន៍ទាយ, ប្រមូលរុក្ខផល , ប្រភេទកីឡាបុរាណ ។ល។

ង. ភាសាដែលអាចមានការឃ្លៀងឃ្លាតពីគ្នាខ្លះក្នុងផ្នែកពាក្យ, ឃ្លា, ការអាន ។ល។

**១.៣** ការស្រាវជ្រាវអំពីបេតិកភណ្ឌវប្បធម៌អរូបី គួរឱ្យមានការចូលរួមពីសហគមន៍ដែលពាក់ព័ន្ធ គឺគួររាប់បញ្ចូលមនុស្សសំខាន់ៗដូចជា មេភូមិ, អាចារ្យ, គ្រូ, ព្រះសង្ឃ, ចាស់ទុំ តាមការស្ម័គ្រចិត្ត។ របាយការណ៍នីមួយៗ គួរឱ្យមានសម្លេងពីអ្នកទាំងនោះមួយចំនួន។ លទ្ធផលទីបញ្ចប់ គួរផ្សព្វផ្សាយតាមបែបបទសមស្របផ្សេងៗ ដើម្បីអ្នកទាំងនោះផ្សព្វផ្សាយបន្តទៀត។

**១.៤** ត្រូវបានទទួលស្គាល់ថា បេតិកភណ្ឌវប្បធម៌អរូបីមានទម្រង់បែបបទច្រើនយ៉ាងណាស់ ប្លែកគ្នាពីសហគមន៍មួយទៅសហគមន៍មួយ ក្នុងនោះគ្មានទម្រង់ណាមួយត្រឹមត្រូវល្អជាងទម្រង់ណាមួយឡើយ។

**១.៥** រាល់ការស្រាវជ្រាវ និងចុះបញ្ជី ត្រូវតែទទួលស្គាល់ថា បេតិកភណ្ឌវប្បធម៌អរូបី តែងតែវិវឌ្ឍន៍ និងប្រែប្រួលជាធម្មតាទៅតាមពេលវេលា។ រីឯការស្រាវជ្រាវនោះ ក៏ត្រូវបញ្ជាក់ពីការប្រែប្រួលនោះ ដែរ។

## ២. សិទ្ធិក្នុងវិស័យវប្បធម៌

**២.១** អាជ្ញាធរអប្សរាទទួលស្គាល់ និងគោរពសិទ្ធិវប្បធម៌របស់បុគ្គលម្នាក់ៗ ដែលជាសិទ្ធិមានចែងនៅក្នុងសិទ្ធិមនុស្សទាំងមូល។ អំពើឬអាកប្បកិរិយាណាមួយរបស់ជនណាម្នាក់ មិនត្រូវទៅរារាំង ទប់ស្កាត់មិនឱ្យអ្នកដ៏ទៃសម្រេចសិទ្ធិក្នុងវិស័យវប្បធម៌របស់គេឡើយ។

**២.២** នៅក្នុងសិទ្ធិទាំងអស់ ក្នុងវិស័យវប្បធម៌ ជនណាក៏ដោយក៏មានសិទ្ធិ :

ក. សិទ្ធិប្រកាន់យកអត្តសញ្ញាណមួយឬច្រើន ទៅតាមប្រវត្តិរបស់ខ្លួន។

ខ. សិទ្ធិប្រតិបត្តិបេតិកភណ្ឌវប្បធម៌របស់ខ្លួន។

គ. សិទ្ធិចូលរួមដោយសេរីក្នុងសកម្មភាពវប្បធម៌របស់សហគមន៍ខ្លួន និងសកម្មភាពវប្បធម៌ជា សាធារ ណៈ។

ឃ. សិទ្ធិគោរពប្រតិបត្តិជំនឿសាសនា។

ង. សិទ្ធិរៀនសូត្រនិងទទួលពត៌មានអំពីវប្បធម៌របស់ខ្លួន។

**២.៣** អាជ្ញាធរអប្សរាគោរពសិទ្ធិនៃសហគមន៍ ដែលកាន់ទំនៀមទម្លាប់ផ្សេងៗ។ ប្រសិនបើបុគ្គលណាម្នាក់ ឬសហគមន៍ណាមួយ មិនអាចប្រកាន់យកបេតិកភណ្ឌវប្បធម៌របស់ខ្លួនបាន ឬមួយប្រសិនបើមានខ្វែងគំនិតគ្នាក្នុងការទទួលស្គាល់សិទ្ធិវប្បធម៌នោះ បើអាចធ្វើទៅបាន អាជ្ញាធរអប្សរាគួរឱ្យអាទិភាពទៅលើវិធីដែលមានជាប្រពៃណី ក្នុងការដោះស្រាយជម្លោះ។

## ៣. សហគមន៍ និងមធ្យោបាយរស់នៅ

**៣.១** អាជ្ញាធរអប្សរាទទួលស្គាល់ថា សហគមន៍ជាច្រើនក្នុងតំបន់អង្គរមានឫសគល់ ទីតាំង និងវប្បធម៌ ដែលមានចំណាស់ច្រើន។ អាជ្ញាធរអប្សរាទទួលស្គាល់ថា សហគមន៍ទាំងនោះស្គាល់របៀបរស់នៅ និងបរិស្ថានរបស់ខ្លួនច្បាស់លាស់។

**៣.២** សហគមន៍ទាំងនេះ ចាក់ឫសជ្រៅទៅនឹងទឹកដីរបស់ខ្លួន ហើយយល់ដឹងច្បាស់អំពីការរស់នៅ និងមធ្យោបាយចិញ្ចឹមជីវិតក្នុងទឹកដីនោះ។ ការយល់ដឹងទាំងនេះ ជាប្រភពដ៏សំខាន់មួយនៃបេតិកភណ្ឌវប្បធម៌អរូបី ធ្វើឱ្យសហគមន៍មានអត្តសញ្ញាណរឹងមាំ ដោយភ្ជាប់ខ្លួនទៅនឹងអតីតកាលផង។ កិច្ចអភិវឌ្ឍន៍សហគមន៍ គួរតែបញ្ចូលការយល់ដឹងរបស់អ្នកស្រុករួមជាគំនិតផង។

**៣.៣** ដរាបណាអាចធ្វើទៅបាន អាជ្ញាធរអប្សរានឹងជួយជំរុញឱ្យមានការបន្តរបៀបរស់នៅ តាមប្រពៃណីនោះ និងឱ្យការប្រើប្រាស់ស្រែដែលមានពីយូរយារមកហើយ ក្នុងក្របខ័ណ្ឌអភិវឌ្ឍន៍សហគមន៍នោះ។ អាជ្ញាធរអប្សរាអាចឱ្យធ្វើការកែប្រែ ឬហាមឃាត់សកម្មភាពរស់នៅខ្លះ ប្រសិនបើមានហេតុផលសមស្របបញ្ជាក់ថាសកម្មភាពទាំងនោះ ប៉ះពាល់ទៅលើបេតិកភណ្ឌវប្បធម៌ដូចជា ប្រាសាទ ឬទេសភាពវប្បធម៌ជាដើម។ កាលណារកឃើញថា សកម្មភាពណាមួយបង្កផលប៉ះពាល់ ពិតប្រាកដ គេត្រូវពិគ្រោះយោបល់ជាមួយសហគមន៍ពាក់ព័ន្ធ។ ដើម្បីរកការសម្រុះសម្រួលគ្នាទៅវិញទៅមក រកវិធានការមកអនុវត្ត។

## ៤. ការអប់រំ

**៤.១** ការអប់រំ និងផ្សព្វផ្សាយអំពីវប្បធម៌ មានសារៈសំខាន់បំផុតក្នុងកិច្ចការពារបេតិកភណ្ឌវប្បធម៌អរូបី។ ការអប់រំនិងបង្កើនការចាប់អារម្មណ៍ ជាមធ្យោបាយយ៉ាងសំខាន់ ដើម្បីបង្កើនការគោរពបេតិកភណ្ឌវប្បធម៌អរូបី។ អាជ្ញាធរអប្សរានឹងជំរុញឱ្យមានការអប់រំ និងការផ្សព្វផ្សាយ ដើម្បីនឹងលើកតម្លៃ បង្កើនចំណាប់អារម្មណ៍លើវប្បធម៌ដែលមានទម្រង់ផ្សេងៗគ្នា ឱ្យមានការគោរព និងប្រតិបត្តិសិទ្ធិវប្បធម៌ត្រឹមត្រូវ។ កម្មវិធីផ្សព្វផ្សាយឱ្យមានការចាប់អារម្មណ៍លើវប្បធម៌ នឹងធ្វើឡើងសម្រាប់បុគ្គលិក-មន្ត្រី នៃអាជ្ញាធរអប្សរាជាមុន។

**៤.២** អាជ្ញាធរអប្សរានឹងផ្សព្វផ្សាយពត៌មានស្តីអំពីរបៀបរស់នៅ និងបេតិកភណ្ឌវប្បធម៌អរូបី និងទម្រង់ផ្សេងៗទៀតដែលមាននៅតំបន់អង្គរ។ អាជ្ញាធរអប្សរានឹងប្រាស្រ័យការងារជាមួយបុគ្គល, ស្ថាប័នអប់រំតាមប្រពៃណី រាប់បញ្ចូលទាំងវត្តអារាម, ការិទេសចរណ៍, ភ្នាក់ងារទេសចរណ៍, មគ្គុទ្ទេសក៍ទេសចរណ៍, ប្រតិបត្តិករទេសចរណ៍, ក្រសួង, ស្ថាប័ននិងអាជ្ញាធរពាក់ព័ន្ធ ក្នុងការរៀបចំកម្មវិធីបណ្តុះបណ្តាល ដើម្បីការយល់ដឹង និងការគោរពបេតិកភណ្ឌវប្បធម៌អរូបីគ្រប់បែបយ៉ាង។ អាជ្ញាធរអប្សរានឹងជំរុញឱ្យមានការបង្កើត, ការអភិវឌ្ឍ, ការផ្សព្វផ្សាយ, ការបង្រៀន, និងឱ្យសហគមន៍នានា បានក្រេបជញ្ជក់យកពត៌មានវប្បធម៌។

**៤.៣** អាជ្ញាធរអប្សរា នឹងផ្សព្វផ្សាយពត៌មានស្តីពីបេតិកភណ្ឌវប្បធម៌អរូបីទៅដល់ភ្ញៀវទេសចរ ដែលមកទស្សនាអង្គរ ដូចជាប្រតិទិនពិធីបុណ្យទានជាដើម។ ចំពោះទីកន្លែងពិសេសខ្លះៗដូចជាទីសក្ការៈ ឬទីតាំងអ្វីមួយដែលជាអត្តសញ្ញាណរបស់ភូមិស្រុកជាដើម អាជ្ញាធរអប្សរានឹងផ្តល់ពត៌មានដល់ភ្ញៀវទាំងអស់ព្រមទាំងដល់អ្នកស្រុកផង តាមមធ្យោបាយផ្សេងៗមានជាអាទិ៍ ស្លាកសញ្ញាជាដើម។ ក្រៅអំពីឱ្យទិន្នន័យសុទ្ធសាធ ពត៌មានទាំងនេះលើកឡើងដើម្បីជម្រុញឱ្យមានការគោរពពីសំណាក់ ជននានាឱ្យសមស្របទៅនឹងទីតាំងនោះ។ ស្លាកសញ្ញាទាំងអម្បាលម៉ាន ត្រូវធ្វើឡើងដើម្បីទទួលស្គាល់ទំនៀមទម្លាប់ជាប្រពៃណីដែលមានរៀងមក និងដើម្បីបន្តឱ្យមានការប្រតិបត្តិតទៅទៀត។

## ៥. ការចូលរួម

**៥.១** អាជ្ញាធរអប្សរាទទួលស្គាល់ថា ការចូលរួមពីសហគមន៍ជាការចាំបាច់ដើម្បីកំណត់, ចងក្រងឯកសារ, ស្រាវជ្រាវ, ថែរក្សា, បង្កើន និងលើកតម្លៃ, ធ្វើឱ្យរស់រវើក និងផ្ទេរបន្តមរតកទៅអ្នកជំនាន់ក្រោយ។ អាស្រ័យហេតុនេះ អាជ្ញាធរអប្សរានឹងខិតខំធ្វើយ៉ាងណា ពិគ្រោះយោបល់ជាប្រក្រតីជាមួយសហគមន៍។

**៥.២** អាជ្ញាធរអប្សរានឹងប្រាស្រ័យការងារជាមួយសហគមន៍ ក្នុងកិច្ចគ្រប់គ្រងបេតិកភណ្ឌអរូបី ដោយចាត់ទុកអ្នកស្រុកថាជាម្ចាស់បេតិកភណ្ឌវប្បធម៌នោះ។ ក្នុងន័យនេះ អាជ្ញាធរអប្សរានឹងពិគ្រោះយោបល់ជាមួយសហគមន៍ ក្នុងការបង្កើត និងអនុវត្តនូវវិធានការគ្រប់គ្រងថែរក្សា មានជាអាទិ៍ កម្មវិធីអប់រំ ឬកម្មវិធីចុះបញ្ជី។

## ៦. ការបង្កើនចំណាប់អារម្មណ៍ពីទេសចរណ៍

**៦.១** អង្គរជារមណីយដ្ឋានដែលមានតម្លៃជាសាកលលើសលប់ និងជាគោលដៅទេសចរណ៍ល្បីល្បាញលើលោក។ តម្លៃនៃអង្គរកើតមកអំពីបេតិកភណ្ឌរូបី និងអរូបីព្រមគ្នា។ កាលបើគេយល់ និងបានសង្កេតដោយផ្ទាល់ហើយ នូវបេតិកភណ្ឌអរូបីគ្រប់បែបយ៉ាងនៃអង្គរ ដូចជាពិធីបុណ្យទាន ឬរបៀបរស់នៅតាមប្រពៃណី។ល។ ការយល់ដឹងនៃភ្ញៀវទេសចរនឹងកាន់តែកើនឡើង។ បេតិកភណ្ឌអរូបីមានតួនាទីវិជ្ជមាន ក្នុងកិច្ចអភិវឌ្ឍន៍ទេសចរណ៍នៅអង្គរ ដូច្នេះ អាជ្ញាធរអប្សរានឹងខិតខំបង្កើនការចាប់អារម្មណ៍ពីទេសចរណ៍។

**៦.២** អាជ្ញាធរអប្សរា ដឹងថាបេតិកភណ្ឌវប្បធម៌អរូបីអាចប្រឈមនឹងគ្រោះថ្នាក់ ដែលអាចកើតឡើងដោយការយកទៅធ្វើអាជីវកម្មមិនត្រឹមត្រូវ ជាការធ្វើឱ្យមានផលប៉ះពាល់អវិជ្ជមានទៅលើបេតិកភណ្ឌ។ អាជ្ញាធរអប្សរានឹងខិតខំធ្វើយ៉ាងណា ឱ្យមានការបង្ហាញបេតិកភណ្ឌអរូបី ក្នុងលក្ខណៈត្រឹមត្រូវ តាមទេសកាល ឬមិនឱ្យខុសនឹងបរិបទ។ ពតិមានពាក់ព័ន្ធអាចបញ្ចូលទៅក្នុងប្រតិទិនពិធីបុណ្យទានប្រចាំឆ្នាំ ដែលចែកផ្សាយដោយសហការណ៍យ៉ាងជិតស្និត ជាមួយនឹងការិទេសចរណ៍, ភ្នាក់ងារទេសចរណ៍, មគ្គុទ្ទេសក៍ទេសចរណ៍, ប្រតិបត្តិករទេសចរណ៍, ក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធ។

**៦.៣** អាជ្ញាធរអប្សរានឹងខិតខំធ្វើយ៉ាងណា មិនឱ្យផលិតផលឬសេវាកម្មផ្សេងៗ ដែលផ្ដល់ដោយ ឬដោយសហការណ៍ជាមួយការីទេសចរណ៍, ភ្នាក់ងារទេសចរណ៍, មគ្គុទ្ទេសក៍ទេសចរណ៍, ប្រតិបត្តិករ ទេសចរណ៍, ក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធ ទៅប៉ះពាល់សិទ្ធិវប្បធម៌នៃសហគមន៍ខ្មែរនានា ឬមួយជះឥទ្ធិពលអវិជ្ជមានលើរបៀបរស់នៅ និងវប្បធម៌អ្នកស្រុក។ អាជ្ញាធរអប្សរា ត្រូវសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធ ដែលជាអាណាព្យាបាលរបស់មគ្គុទ្ទេសក៍ទេសចរណ៍ ក្នុងការរៀបចំ និងលើកតម្លៃបេតិកភណ្ឌអរូបី តាមលក្ខណៈត្រឹមត្រូវ ត្បិតមគ្គុទ្ទេសក៍មានការពាក់ព័ន្ធផ្ទាល់ នឹងបេតិកភណ្ឌនេះ ដោយសារអាជីពរបស់ខ្លួននៅក្នុងវិស័យទេសចរណ៍។

**៦.៤** អាជ្ញាធរអប្សរាត្រូវណែនាំការីទេសចរណ៍, ភ្នាក់ងារទេសចរណ៍, មគ្គុទ្ទេសក៍ទេសចរណ៍, ប្រតិបត្តិករទេសចរណ៍, ក្រសួង, ស្ថាប័ននិងអាជ្ញាធរពាក់ព័ន្ធ ឱ្យពិគ្រោះយោបល់ជាមួយសហគមន៍ ដែលជាម្ចាស់បេតិកភណ្ឌ មុននឹងយកបេតិកភណ្ឌមកបម្រើឱ្យវិស័យទេសចរណ៍ ហើយម្យ៉ាងទៀត ដើម្បីបានជាផលប្រយោជន៍ដល់អ្នកស្រុកផង។

## ៧. ការទទួលស្គាល់

**៧.១** អ្នកស្រុកដែលមានចំណេះដឹងពីបេតិកភណ្ឌអរូបី ជាមនុស្សសំខាន់ក្នុងសហគមន៍របស់ខ្លួន ក្នុងការរក្សា និងបន្តបេតិកភណ្ឌនោះទៅអ្នកជំនាន់ក្រោយ, ក្នុងការបង្កើត និងធ្វើឱ្យរស់រវើកឡើងវិញ នូវអ្វីដែលបាត់បង់ទៅហើយ។ និរន្តភាពនៃបេតិកភណ្ឌអរូបី អាស្រ័យទៅលើការប្រាស្រ័យទាក់ទងជាប្រចាំរវាងមនុស្សដែលមានចំណេះដឹង ទៅជំនាន់ក្រោយៗទៀត។

៧.២ អាជ្ញាធរអប្សរានឹងទទួលស្គាល់អ្នកស្រុកដែលមានចំណេះដឹងអំពីបេតិកភណ្ឌខ្លួន ហើយជំរុញឱ្យមានការបន្តចំណេះអំពីប្រពៃណីនោះ។ អាជ្ញាធរអប្សរានឹងពិគ្រោះយោបល់ជាមួយមនុស្សសំខាន់ ដែលមានចំណេះអំពីបេតិកភណ្ឌអរូបី ដើម្បីរៀបចំគ្រប់គ្រងបេតិកភណ្ឌនោះ។ អាជ្ញាធរអប្សរាអាចទទួលស្គាល់ និងអាចស្នើសុំឱ្យស្ថាប័នមានសមត្ថកិច្ច ទទួលស្គាល់អ្នកដែលមានចំណេះដឹងពិសេសនោះ។

## ៨. ការពិនិត្យឡើងវិញ

៨.១ លំនាំបទដ្ឋាននៃអាជ្ញាធរអប្សរាក្នុងការថែរក្សាបេតិកភណ្ឌអរូបី អាចនឹងសើរើពិនិត្យឡើងវិញ។ គណៈកម្មការពាក់ព័ន្ធមួយអាចនឹងបង្កើតឡើង ដោយមានតំណាងពីនាយកដ្ឋានផ្សេងៗ (តាមរចនាសម្ព័ន្ធបច្ចុប្បន្ន) ដូចជានាយកដ្ឋានអភិវឌ្ឍន៍កសិកម្ម និងសហគមន៍, នាយកដ្ឋានរៀបចំដែនដី និងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរ, នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរ, នាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌ សារមន្ទីរ និងបទដ្ឋានបេតិកភណ្ឌ, នាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការ, នាយកដ្ឋានអភិរក្សប្រាសាទក្រៅឧទ្យានអង្គរ, នាយកដ្ឋានគ្រប់គ្រងទឹក, នាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន, នាយកដ្ឋានផ្សព្វផ្សាយ, ព្រមទាំងមនុស្សសំខាន់ៗនៅក្នុងសហគមន៍ដូចជា អាចារ្យ, ព្រះសង្ឃ, គ្រូ។ល។ គណៈកម្មការពិនិត្យឡើងវិញនេះ អាចនឹងតាមដានប្រសិទ្ធិភាពយន្តកម្ម នៃបទដ្ឋាននេះ ហើយអាចនឹងស្នើកែសម្រួល កម្មវិធី ឬបទដ្ឋានការពារ ទៅតាមការសង្កេតនោះ។

៨.២ ក្នុងការពិនិត្យឡើងវិញនេះ អាជ្ញាធរអប្សរាអាចអញ្ជើញតំណាងសហគមន៍ខ្លះនៅតំបន់អង្គរ ធ្វើជាសមាជិកនៃយន្តកម្មនេះ និងធ្វើសំណើផ្សេងៗស្តីពីការការពារ, ការរួមចំណែក ឬការកែប្រែលំនាំបទដ្ឋាននៃការការពារបេតិកភណ្ឌអរូបីនៅតំបន់សៀមរាប-អង្គរ។

## Editor :

KHUON Khun-Neay

## Technical Group for the Guidelines :

| | |
|---|---|
| CHAU SUN Kériya | Advisor |
| KHUON Khun-Neay | Advisor |
| HANG Peou | Advisor |
| ANG Choulean | Chair |
| IM Sokhrithy | Vice Chair |
| EAR Darith | Member |
| KHIEU Chan | Member |
| SRUN Tech | Member |
| HENG Than | Member |
| HENG Sokha | Member |
| EM Kimsreang | Member |
| KIM Samnang | Member |

## Consultant :

Georgina LLOYD

## Layout and Design :

HOR Rithearath — IT Specialist


## Contents :


EDITOR'S NOTE ........ 18

PURPOSES OF THE GUIDELINES ........ 20

REFERENCE ........ 20

POLICY TO SAFEGUARD INTANGIBLE CULTURAL HERITAGE ........ 22

1. Research and Inventory ........ 22
2. Cultural Rights ........ 23
3. Community and Livelihoods ........ 24
4. Education ........ 25
5. Participation ........ 26
6. Tourism Awareness ........ 26
7. Recognition ........ 27
8. Review ........ 27



Supported by the New Zealand Aid Program

NEW ZEALAND

# GUIDELINES

## Safeguarding Intangible Cultural Heritage within the Angkor World Herigage Site and other Sites under the Jurisdiction of APSARA Authority

1 July 2013

United Nations Educational, Scientific and Cultural Organization

Intangible Cultural Heritage

អាជ្ញាធរអប្សរា
APSARA

# EDITOR'S NOTE

The APSARA Authority is responsible for safeguarding Angkor Park, so that it is managed in conformity with UNESCO Conventions, enhancing the tangible and the intangible cultural heritages. This is done with an understanding that the living intangible heritage could not be separated from tangible heritage: just as we could not separate the soul of human being from the body unless when the person is dead.

Nowadays, our intangible heritage is disappearing little by little. Without understanding and preservation of the intangible heritage we still have we could lose the identity of the nation. Since 2000 the APSARA Authority has deployed tremendous effort in conducting research and establishing inventory of different forms of intangible heritage in the Angkor Park by founding a research group named **"Social Studies Group"**. This activity was included in the **"Living with Heritage"** project in collaboration with the University of Sydney, Australia. In 2009, this research group's activities were also incorporated into the **"Angkor Participatory Natural Resource Management and Livelihoods (APNRM&L)"** programme, jointly administered by APSARA and New Zealand.

Alongside these activities, on April 22, 2010, the APSARA Authority founded a research group called **"Research on Intangible Heritage in the Angkor Park"**. This group concentrated its effort in drafting the **"Guidelines for Safeguarding Intangible Cultural Heritage within the Angkor World Heritage Site and other Sites under the Jurisdiction of APSARA Authority"**. On August 13, 2010 this document was reviewed and supported by leaders of the APSARA Authority.

The APSARA Authority organized a seminar on July 1, 2013 in order to submit the draft guidelines for wider consultation, including the participation of monks, achars, Buddhist monastery committee members, provincial and local authorities, tourist guides and elders from the villages in the Angkor Park. After discussion and some improvements, the seminar adopted the **"Guidelines for Safeguarding Intangible Cultural Heritage within the Angkor World Heritage Site and other Sites under the Jurisdiction of APSARA Authority"**. These guidelines constitute a solid mechanism for implementation of intangible heritage management in the Angkor Park.

It is very important to have such a mechanism, but it is absolutely necessary to get the understanding and cooperation of all stakeholders e.g. all level of governmental authorities and the population, to assure the full implementation of this mechanism.

This booklet aims to enhance understanding of the general public and other key stakeholders about the important task of safeguarding our intangible heritage.

Siem Reap, July 1st, 2013

Khuon Khun-Neay
Deputy Director-General of APSARA Authority
in charge of Department of Land and Habitat Management in the Angkor Park
Chairperson of the Technical Committee for the implementation of the APNRAM&L Programme






## PURPOSES OF THE GUIDELINES

**The purposes of this policy are:**

(i) To safeguard intangible cultural heritage, which cannot be separated from tangible heritage, at Angkor and other sites under the jurisdiction of the APSARA Authority.

(ii) To recognise the right and freedom of all villagers to their intangible heritage and their duty to respect, protect and receive benefits from their heritage.

(iii) To raise awareness on the safeguarding intangible and tangible heritage, in compliance with UNESCO Conventions. Particularly, to raise awareness within the APSARA Authority and the wider public of the importance of intangible cultural heritage and Cambodia's obligation to safeguard this heritage.

(iv) To encourage respect and promote the value of intangible cultural heritage which is a unique part of Cambodia's rich heritage and is a source of national identity.

## REFERENCE

- **Recognising** that Cambodia is a signatory to the Convention Concerning the Protection of the World Cultural and Natural Heritage (1972) and the Convention for the Safeguarding of the Intangible Cultural Heritage (2003),
- **Realising** that both these Conventions protect important elements of heritage present at Angkor and must be implemented to ensure the future of Cambodia's unique cultural heritage,
- **Recognising** the UNESCO convention on the Protection and Promotion of the Diversity of Cultural Expressions (2005),

- **Referring** to Royal Decree No NS/RKM0106/003/ dated January 18, 2006 on Promulgation of Law on the Adoption of the Convention for the Safeguarding of the Intangible Cultural Heritage,
- **Referring** to Royal Decree No SN/RKM/0707/019 dated July 20, 2007 Royal Kram No NS/0707/019 promulgating the Law on Adoption of the Kingdom of Cambodia's signing of the Convention on the Protection and Promotion of the Diversity of Cultural Expressions,
- **Referring** to Royal Decree No 001/NS dated May 28, 1994 establishing Protected Cultural Zones in the Siem Reap/Angkor Region and Guidelines for their Management,
- **Referring** to Royal Decree No NS/RKT/0295/12 dated February 19, 1995 establishing the Authority for the Protection and Management of Angkor and the Region of Siem Reap, named the APSARA Authority and the subsequent amendments,
- **Referring** to Decision No 70/SSR dated November 16, 2004 on Determination of Standards for Utilization of Land in Zones 1 and 2 of Siem Reap/Angkor Sites,
- **Referring** to Royal Decree No NS/RKM/0196/26 dated January 25, 1996 establishing Law on the Protection of Cultural Heritage,
- **Referring** to Royal Decree No SN/RKT/0210/163 dated February 16, 2010 establishing Living Human Treasures System of the Kingdom of Cambodia,
- **Referring** to Sub-Decree No 50/ANK/BK dated May 9, 2008 establishing that the APSARA Authority has the task to safeguard traditional habitat and religious constructions, ensure compliance with UNESCO Conventions, disseminate knowledge and research on Khmer culture, increase awareness on heritage values, develop respect for heritage and promote tangible and intangible Khmer culture,
- **Acknowledging** the proclamation of UNESCO to register Khmer Royal Ballet (07/11/2003) and Sbek Thom (25/11/2005) as Masterpieces of the Oral and Intangible Heritage of Humanity,

- **Aware** that the continuation of intangible cultural heritage is essential to maintain the spiritual value of Angkor,
- **Recognising** that there is an organic link between the Angkor World Heritage Site and its people,
- **Understanding** that it is normal that there is an ongoing use of the monuments by local communities for religious and ritual practice.

## THE FOLLOWING POLICY TO SAFEGUARD INTANGIBLE CULTURAL HERITAGE IS ADOPTED :

### 1. Research and Inventory

**1.1** Research is fundamental to understanding and appreciating intangible heritage. A research programme shall be established that sets out to understand all forms of intangible cultural heritage present in areas managed by the APSARA Authority. A research team shall be created whose specific task is to document intangible cultural heritage within all the areas managed by the APSARA Authority.

**1.2 The Angkor intangible heritage includes, but is not limited to :**

**a)** **Orally transmitted knowledge,** such as myths, tales, legends (including village and community histories and place names), proverbs, traditional words, songs.

**b)** Forms of **artistic representation** such as murals, puppetry, all forms of theatre, dance, music.

Ceremonies and rituals of all forms (Animistic, Buddhist, Brahmanic, often syncretised with one another) and for all purposes (rites of passage, agrarian rites, construction rites).

c) **Ceremonies and rituals** of all forms (Animistic, Buddhist, Brahmanic, often syncretised with one another) and for all purposes (rites of passage, agrarian rites, construction rites).

d) **Traditional knowledge** or **skills about craft,** vernacular architecture, cooking, healing, astrology and fortune telling, collecting forest products, traditional forms of sport, etc.

e) **Dialectal features of language** (accent, vocabulary, idiomatic expressions).

**1.3** Research should involve the consultation of the local community. Within each village, key members of society such as the village leader, achar, kru, monk, elderly villagers, should be asked on a voluntary basis to share information about intangible cultural heritage. A set number of village members should directly influence the content of any research report. All research outcomes should be provided to the village in an appropriate form for them to disseminate.

**1.4** It is recognised that there is vast variation in forms of intangible cultural heritage practiced by communities. No one form is more valid than another and any research will try to encompass and acknowledge this variation.

**1.5** Any research or inventory should accept that intangible heritage changes over time. Change should be accepted as an integral element of intangible heritage and any research should clarify and incorporate this.

## 2. Cultural Rights

**2.1** The APSARA Authority should recognise and respect the cultural rights of an individual which are rights established in global human rights. Any act or behaviour by any person shall not restrict or prevent an individual’s ability to realise these rights.

**2.2 Within the globally accepted corpus of cultural rights all people have :**

- **a)** The right to identify oneself with one or several cultural communities according to their histories.
- **b)** The right to access heritage.
- **c)** The right to participate freely in cultural life and public cultural policy.
- **d)** The right to religious belief and practice.
- **e)** The right to education and information about their culture.

**2.3** The APSARA Authority respects the rights of communities that practice forms of traditions. If an individual or community can not realise their cultural rights or there is a dispute arising from the recognition of cultural rights, the APSARA Authority should give priority to, and where possible adhere to, traditional methods of dispute resolution.

## 3. Community and Livelihoods

**3.1** The APSARA Authority recognises that many communities around Angkor site have ancient foundations, cultural roots and are very old. The APSARA Authority acknowledges that these communities know very well their traditional livelihoods and environment.

**3.2** These communities have been dwelling for a very long time in their place and understand very well about their traditional living and livelihood of their village. This understanding is one of the important sources of intangible cultural heritage which makes these communities strongly identify with the past. The development of communities should incorporate the traditional knowledge of the villagers.

**3.3** As far as possible, APSARA Authority shall encourage the continuation of traditional livelihoods and the use of ancestral rice fields in the development of communities. APSARA Authority reserves the right to change or prevent the activities if there is

justifiable evidence that the activities are directly impacting heritage entities such as temples or cultural landscape. When it is found that an activity causes significant impacts, the community should be consulted together with the involved authority to mutually agree measures that should be implemented.

## 4. Education

**4.1** Education and dissemination of information about culture are central to the safeguarding of intangible cultural heritage. Education and awareness-raising are important tools for the development of respect for intangible cultural heritage. The APSARA Authority will encourage the use of education and information to promote cultural diversity, cultural awareness, respect and the fair exercise of cultural rights. An awareness-raising program shall be conducted for the staff of the APSARA Authority.

**4.2** The APSARA Authority will disseminate information about traditional livelihoods and other forms of intangible cultural heritage present at Angkor. The APSARA Authority will work with individuals, traditional education institutions, including monasteries, tourism guides, tour agencies, tour operators, ministries, institutions and associations to organise the training programmes to understand and respect the intangible cultural heritage. The APSARA Authority shall also encourage the creation, development, distribution, teaching and consumption of cultural information by local communities.

**4.3** The APSARA Authority will distribute information about intangible cultural heritage, such as an annual calendar of traditional events, to visitors to the Angkor World Heritage Site. For some special locations or places which is the identity of ancient village the APSARA Authority will inform visitors and the local community through several means including signage. Such information should encourage respectful behaviour appropriate to the location. All signs should acknowledge the traditions and customs which existed a long time ago and their continuation.

## 5. Participation

**5.1** APSARA Authority acknowledges that community participation is critical for the identification, documentation, research, preservation, promotion, enhancement, transmission of knowledge to the next generation of intangible cultural heritage. So APSARA Authority will endeavour to develop regular and systematic consultation with local communities.

**5.1** The APSARA Authority will actively engage the community in the management of intangible cultural heritage by ensuring that community members are bestowed custodianship of their intangible heritage. Therefore APSARA Authority should consult with the community to develop or implement the safeguarding measures such as education programmes and inventory programmes.

## 6. Tourism Awareness

**6.1** Angkor is a site of outstanding universal value and a world-renowned tourism destination. The value of Angkor stems from both its tangible and intangible heritage. Understanding and experiencing the intangible cultural heritage of Angkor in all its forms, including local ceremonies, traditional livelihoods etc, will enhance the experience of visitors. Intangible cultural heritage has a positive role to play in the development of tourism at Angkor and as such the APSARA Authority shall work towards increasing tourism awareness.

**6.2** The APSARA Authority is aware that intangible cultural heritage can be at risk of commercialisation and modification and such processes can have negative impacts on heritage. The Authority will attempt to ensure that intangible cultural heritage is presented in an authentic manner and is not removed from its appropriate context. This may be incorporated into an annual calendar of traditional events distributed in association with tour operators, tour agencies, tour guides, ministries or any authority which is involved.

**6.3** The APSARA Authority shall ensure that any goods or services supplied by or associated with tour operators, tour agencies, tour guides, ministries, institutions, or any authority which is involved do not impair the cultural rights of Cambodian communities or cause significant negative influences on the ways of life or cultural expressions of members of these communities. The APSARA Authority shall involve, and cooperate with, ministries, institutions or any involved authority coordinating tourism guides to appropriately promote and manage intangible heritage as guides are directly interacting with this heritage as part of the tourism sector.

**6.4** The APSARA Authority should give advice to tour operators, tour agencies, tour guides, ministries and other involved authorities to consult with communities before using their heritage within the tourism sector and to ensure that the community benefits.

## 7. Recognition

**7.1** The villagers who have knowledge about intangible heritage are very important in their community in safeguarding and transmission and in recreation and revitalisation of heritage. The continuance of intangible heritage depends upon the maintenance of dialogue between holders of knowledge and the younger generations.

**7.2** The APSARA Authority will recognise the holders of knowledge and stimulate transmission of traditional knowledge. APSARA Authority will consult with key holders of knowledge for the management of intangible cultural heritage. The APSARA Authority may recognise and propose that special holders of knowledge be recognised by the appropriate authority.

## 8. Review

**8.1** The intangible heritage safeguarding policy of the APSARA Authority is subject to review. A review committee may be formed with representatives from departments of the APSARA Authority such as (under the current structure of the APSARA Authority) the Department

of Agriculture and Community Development, Department of Land and Habitat Management, Department of Angkor Tourism Development, Department of Cultural Development, Museums and Heritage Norms, Department of Conservation of Monuments in the Angkor Park and Preventive Archaeology, Department of Conservation of Monuments Outside of the Angkor Park, Department of Water Management, Department of Forestry, Cultural Landscapes and Environmental Development, Department of Communication and key representatives from local communities such as achar, monks, kru. This review committee may monitor the effectiveness of current safeguarding mechanisms and propose amendments to safeguarding programmes or the policy document.

**8.2** Local communities in Angkor may be invited to make submissions to the review committee stating the mechanisms undertaken to safeguard intangible cultural heritage, suggestions for the safeguarding of intangible heritage and/or contributions/ alterations to the safeguarding policy of safeguarding of intangible heritage in Siem Reap-Angkor.












United Nations
Educational, Scientific and
Cultural Organization

Intangible
Cultural
Heritage

APSARA

អាជ្ញាធរដើម្បីការពាររមណីយដ្ឋាន
និងរៀបចំតំបន់ សៀមរាប-អង្គរ

Authority for the Protection and the Management
of Siem Reap Region

www.autoriteapsara.org

